# អនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី

(ចង្វាក់ សារ៉ាវ៉ាន់) កែសម្រួលដោយក្រសួងវប្បធម៌ (២)

១- សម្តេចនាយករដ្ឋមន្ត្រី អគ្គមហាសេនាបតីតេជោហ៊ុនសែន
លើកអនុសាសន៍ប្រសើរពិតមែន ឱ្យមនុស្សរាប់សែនបានពិចារណា ។

២- ទី១ ឱ្យយកតាមព្រះរាជសារ ពីអង្គស្តេចខ្មែរក្សត្រីជ័យា
តាមដានផ្សព្វផ្សាយពិនិត្យត្រួតត្រា រដ្ឋាភិបាលពិចារណ៍អនុម័ត ។

៣- ទី២ ណែនាំឱ្យទីស្តីការ បន្តឃោសនាឱ្យបានមធ្យ័ត
គ្រប់ផ្នែកពាក់ព័ន្ធរាយការណ៍ម៉ត់ចត់ ដោយប្រុងប្រយ័ត្នការងារជាក់ច្បាស់ ។

៤- ទី៣ បោះដៃការងារបន្ទាន់ ក្រសួងហិរញ្ញវត្ថុរួសរាន់ វិច ខ្ចប់
រៀបខ្ទង់ថវិកាឱ្យច្បាស់លាស់ ឆ្លើយតបរហ័សទៅលើយេនឌ័រ ។

៥- ទី៤ អង្រួនក្រសួងថវិកា សេដ្ឋកិច្ចដុល្លារសព្វអន្លើ
កិច្ចការនារីគឺជាអ្នកធ្វើ បទពិសោធន៍ទៅលើគ្រប់គ្រងនៅដៃ ។

៦- ទី៥ មុខងារសាធារណៈ កំណត់ឱ្យជាក់ជ្រើសរើសមន្ត្រី
ត្រូវផ្តល់ឱកាសឱ្យទៅលើស្ត្រី ទទួលកៅអីនៅក្នុងការងារ ។

៧- មន្ត្រីស្ត្រីនឹងបានរុងរឿង ព្រោះសម្តេចយើងបានចេញមាត្រា
បើខ្វះកូរ៉ុម ត្រូវទុកទំនេរ កូតាស្ត្រីទេមិនអាចផ្លាស់ប្តូរ ។

៨- ៦ បង្ក្រាបនូវរាល់បទល្មើស មានកុនអាសអាភាសហើយនិងវីដេអូ
ខារ៉ាអូខេប៉ះពាល់វប្បធម៌ កិត្តិយសឈ្មោះខ្មែរអាប់អោនដល់ស្ត្រី ។

៩- ទាក់ទងដំណែងដែលចែងក្នុងច្បាប់ សម្តេចរ៉ាយរ៉ាប់ប្រាប់ទៅមហាផ្ទៃ
ពិនិត្យកូតាតួនាទីស្ត្រី រដ្ឋបាលដែនដី ពិតប្រាកដជាក់ ។

១០- ៧ សំភីត្រូវតែប្រឹងប្រែង បង្ក្រាបកន្លែងដែលសេពសន្ថវៈ
ឱ្យសមត្ថកិច្ចយើងមានចំនឿជាក់ គ្មានដីកាស្ទ័គ្រ ក៏អាចធ្វើបាន ។

១១- ៨ គ្រប់គ្រងនូវរាល់អាវុធជាតិផ្ទុះ ពីក្មេងពាលនោះកុំបីខកខាន

ដាវសាំម៉ូរ៉ៃ ពូថៅសាមាន្យ ឱ្យស្រុកភូមិដ្ឋានស្រស់បស់ប្រិមប្រិយ ។

១២- ដីកាចុងក្រោយគឺមិនត្រូវធ្វេស ខ្មែរបានបរទេសយកធ្វើជាប្ដី
ច្រើនតែបោកប្រាស់យកព្រហ្មចារីយ៍ ចូលក្នុងរឿងក្ដីនៃការជួញដូរ ។

១៣- ដូចនេះក្រសួងពាណិជ្ជកម្ម ត្រូវលុបអាជ្ញាប័ណ្ណចេញជាស្ថាពរ
ដើម្បីរក្សាវប្បធម៌ថ្លៃថ្នូរ តាំងពីអង្គខ្មែរធ្លាប់ត្រចះ ។

១៤- អនុសាសន៍នេះមានន័យគ្រប់គ្រាន់ ក្រសួងពាក់ព័ន្ធត្រូវចេះរិះត្រិះ
សង្គមខ្មែរល្អព្រោះតែតម្រិះ សម្ដេចតេជះនាំជាតិរុងរឿង ។

*ដកស្រង់ចេញពីខ្លឹមសារដើមនៃអនុសាសន៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឱកាសប្រជុំបូកសរុបការងារប្រចាំឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។*